ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត

ខេត្តកំពត ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥

សូមគោរព :

- ឯកឧត្តម ខុយ ឃុនហ៊ួរ អភិបាល នៃគណៈអភិបាលខេត្តកំពត
- ឯកឧត្តម កែន សត្ថា អភិបាល នៃគណៈអភិបាលខេត្តកែប
- ឯកឧត្តម អ៊ឹង ម៉េងហួរ ប្រធានក្រុមប្រឹក្សាខេត្តកំពត
- ឯកឧត្តម សំ សារីន ប្រធានក្រុមប្រឹក្សាខេត្តកែប
- លោក Hervé Dallerac ទីប្រឹក្សាទូទៅថ្មីរបស់ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា
- លោក Dong Hyun Choi ទីប្រឹក្សាធនាគារកណ្តាលកូរ៉េប្រចាំនៅធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការ អគារសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពត ជាផ្លូវការ ស្របពេលដែលរាជរដ្ឋាភិបាលអនុញ្ញាតឱ្យអាជ្ញាធរខេត្តកំពតត្រៀមលក្ខណៈរៀបចំពិធីបុណ្យសមុទ្រ នៅថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ ។ អគាររបស់ធនាគារជាតិនៃកម្ពុជា ខេត្តកំពតនេះ គឺជាផ្នែកមួយនៃការរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងចូលរួមចលនាប្រឡងប្រណាំងទីក្រុងស្អាត របស់រាជរដ្ឋាភិបាលកម្ពុជា និងជាពិសេស ជាការកសាងសមិទ្ធផលផ្នែកសង្គមនិងវិស័យធនាគារថ្មីមួយបន្ថែមទៀត សម្រាប់ប្រជាជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និវត្តជន និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅខេត្តកំពតនិងខេត្តកែបប្រើប្រាស់ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកំពតនិងខេត្តកែប តំណាងមន្ទីរ-អង្គភាព និងអាជ្ញាធរមានសមត្ថកិច្ចជុំវិញខេត្តកំពតនិងខេត្តកែប ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងបង្កបរិយាកាសល្អឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបអាជីវកម្មប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ។ ស្មារតីកិច្ចសហប្រតិបត្តិការជាប្រពៃណីនេះ គឺជាកត្តាគន្លឹះ ធ្វើឱ្យការងាររបស់យើងទទួលបានជោគជ័យជានិច្ច ។



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

តាមរយៈរបាយការណ៍របស់ ឯកឧត្តម ខូយ ឃុនហួរ អភិបាលនៃគណៈអភិបាលខេត្តកំពត និងឯកឧត្តម កែន សត្ថា អភិបាលនៃគណៈអភិបាលខេត្តកែប ខ្ញុំសូមចូលរួមអបអរសាទរចំពោះសមិទ្ធផលអភិវឌ្ឍន៍រីកចម្រើនលើគ្រប់ផ្នែក ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចនិងសង្គមនៅទូទាំងខេត្ត ។ ខ្ញុំកត់សម្គាល់ឃើញថា ខេត្តនៅជាប់សមុទ្រទាំងពីរនេះ ជាខេត្តមានសក្តានុពលសេដ្ឋកិច្ចផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម និងនេសាទសមុទ្រដែលអាចផ្គត់ផ្គង់គ្រប់គ្រាន់និងធានាបានសុវត្ថិភាពស្បៀងជាពិសេស ដំណាំស្រូវ ផល្លានុផល ផ្លែឈើ ផលិតផលសមុទ្រ និងផលិតផលម្រេចដែលទទួលបានចំណាត់ថ្នាក់លេខ១ជាសកល ។ មិនតែប៉ុណ្ណោះ ខេត្តនេះក៏ជាខេត្តដែលមានសក្តានុពលផ្នែកឧស្សាហកម្ម ដូចជារោងចក្រផលិតស៊ីម៉ង់ ចំណីសត្វ និងអំបិល និងជាតំបន់ទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ដែលបានរួមចំណែកលើកស្ទួយវិស័យទេសចរណ៍នៅកម្ពុជា ។ ដោយមានលក្ខខណ្ឌអំណោយផល ខេត្តកំពតនិងខេត្តកែបគឺជាតំបន់គោលដៅសម្រាប់វិនិយោគិនលើវិស័យកសិកម្ម ថាមពលវារីអគ្គិសនី ការអភិវឌ្ឍតំបន់ឆ្នេរ ផលិតកម្មកែច្នៃផលិតផលសមុទ្រ ប្រព័ន្ធធារាសាស្ត្រ អេកូទេសចរណ៍ផងដែរ ។

តាមរយៈរបាយការណ៍របស់លោកនាយកសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពត ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពតដែលត្រូវបានសាងសង់ថ្មីនេះ នឹងឆ្លើយតបបានយ៉ាងល្អប្រសើរចំពោះការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចខេត្តនាពេលបច្ចុប្បន្ន និងតម្រូវការចាំបាច់នានា ក្នុងការគ្រប់គ្រងនិងសម្រួលប្រតិបត្តិការរូបិយវត្ថុ សំដៅជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត ។ អគារនេះត្រូវបានសាងសង់ឡើង ដោយគ្រប់បន្ទប់ធ្វើការបំពាក់នូវប្រព័ន្ធកុំព្យូទ័រ ហើយផ្នែកខាងក្នុងនិងខាងក្រៅអគារត្រូវបានបំពាក់ដោយប្រព័ន្ធសុវត្ថិភាពទំនើប ។ ចាប់ពីថ្ងៃនេះ តទៅ សាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពត នឹងបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់សេវារូបិយវត្ថុ និងជួយសម្រួលដល់ប្រតិបត្តិការទូទាត់ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរ-អង្គភាពរបស់រដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសាធារណជនទូទៅ ព្រមទាំងធ្វើជាឃ្លាំងផ្ទុកទ្រព្យសម្បត្តិរដ្ឋប្រចាំខេត្តកំពតនិងខេត្តកែប ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបអំពីការអភិវឌ្ឍរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ចនិងវិស័យធនាគារនៅកម្ពុជា ។ ស្ថិតក្នុងបរិយាកាសអំណោយផលនៃសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរកន្លងមក សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ដោយរំពឹងថានឹងសម្រេចបានកំណើន ៦,៩% ក្នុងឆ្នាំ២០១៥ ដែលនឹងធ្វើឱ្យកម្ពុជារួចផុតពីប្រទេសមានចំណូលទាប ហើយក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមនៅឆ្នាំ២០១៦ខាងមុខនេះ ។

កំណើនសេដ្ឋកិច្ចដ៏រឹងមាំនេះ គាំទ្រជាចំបងដោយកំណើននៃការនាំចេញក្នុងឧស្សាហកម្មកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍ ។ អត្រាអតិផរណាមានកម្រិតក្រោម ២% ដែលជាកម្រិតមួយទាប ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក បន្តមានស្ថិរភាពស្ថិតក្នុងរង្វង់ ៤.០០០ រៀលក្នុងមួយដុល្លារ និងប្រែប្រួលបន្តិចបន្តួចទៅតាមរដូវកាលប៉ុណ្ណោះ ។

ចំណែកឯវិស័យធនាគារក៏មានការរីកចម្រើន ទាំងផ្នែកវិសាលភាពនិងទំហំប្រតិបត្តិការ និងបានបន្តគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។ ប្រព័ន្ធធនាគារនៅកម្ពុជា បាននិងកំពុងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ក្នុងការកៀរគរនិងបែងចែកមូលនិធិសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ដោយបំពេញបន្ថែមដើមទុនទៅឱ្យសហគ្រាស ក្រុមហ៊ុន ឬអាជីវកម្មខ្នាតតូចសម្រាប់គម្រោងវិនិយោគនិងពង្រីកផលិតកម្មរបស់ខ្លួន ក្នុងអត្រាការប្រាក់សមរម្យ។ ការផ្តល់និងទទួលបានសេវាឥណទាននិងសេវាហិរញ្ញវត្ថុផ្សេងៗទៀត បានបន្តកើនឡើងជាលំដាប់ ដែលបានបង្ហាញថា សាធារណជនកាន់តែយល់ដឹងច្រើនឡើងពីវប្បធម៌ឥណទាន និងសារៈសំខាន់ក្នុងការស្វែងរកនិងប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុក្នុងជីវភាពប្រចាំថ្ងៃ ក៏ដូចជាទទួលបានសេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយផងដែរ ។

ជាក់ស្តែង តាមរយៈរបាយការថ្មីៗនេះ បានបញ្ជាក់ថា មានប្រជាជនអាយុលើស ១៥ឆ្នាំ ប្រមាណ ៤៦% ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ធៀបនឹង ១៩% កាលពី ៥ឆ្នាំមុន ។ ប្រតិបត្តិការនិងសាខារបស់គ្រឹះស្ថានធនាគារត្រូវបានពង្រីកឥតឈប់ឈររហូតដល់ ៥៨៦ សាខា ព្រមទាំងមានម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) ជាង ១,០០០ កន្លែងនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដើម្បីសម្រួលដល់ការដក ដាក់ និងផ្ទេរប្រាក់របស់ប្រជាពលរដ្ឋ ។ ចំណែកឯទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារបានកើនឡើងដល់ ១៥ពាន់លានដុល្លារអាមេរិក ស្មើនឹង ១០៣% នៃផ.ស.ស ខណៈដែលប្រាក់បញ្ញើបានកើនឡើងដល់ប្រមាណ ១១ ពាន់លានដុល្លារ និងឥណទានចំពោះវិស័យឯកជនក៏បានកើនឡើងដល់ប្រមាណ ១១ពាន់លានដុល្លារអាមេរិកផងដែរ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ មានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំង មានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ហើយជាឧបករណ៍គោលនយោបាយរដ្ឋាភិបាលសម្រាប់រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូចជូនប្រជាជននិងសហគ្រាសធុនតូចនិងមធ្យម នៅទូទាំងប្រទេស ជាពិសេសនៅតំបន់ជនបទ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនស្របតាមយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។ គួរឱ្យកត់សម្គាល់ថា ក្នុងអំឡុងពេលមួយទសវត្សនេះ ទ្រព្យសកម្មវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ពី ១% ដល់ ១៨% នៃផ.ស.ស នៅឆ្នាំ២០១៥ នេះ ។